**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែតុលា ឆ្នាំ២០១៦

នៅក្នុងខែតុលា ឆ្នាំ២០១៦នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន:**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០១លើក

-អញ្ជើញជាអធិបតីក្នុងឱកាសបើកវេទិកាស្ត្រី ស្ដីពីវឌ្ឍនភាពស្ត្រីក្នុងវិស័យនយោបាយ

-អនុញ្ញាតឲ្យលោកជំទាវ NGUYEN THI KIM NGAN ប្រធានរដ្ឋសភា និងគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្ដែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម Xiang Bo ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យប្រតិភូយុវជននៃសមាគមនារីយុវជនអាស៊ីអាគ្នេយ៍កម្ពុជា ចូលជួបសម្ដែងការគួរសម និងសុំអនុសាសន៍ណែនាំ

-អនុញ្ញាតឲ្យប្រតិភូយុវជនកម្ពុជាក្នុងកម្មវិធីអ្នកដឹកនាំវ័យក្មេងអាស៊ាន ចូលជួបសម្ដែងការគួរសម និងសុំអនុសាសន៍ណែនាំ

-អញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីបុណ្យខួបគម្រប់៤ឆ្នាំ នៃការយាងចូលព្រះ**ទិវង្គត ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ "** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៅព្រះធម្មសាលាក្នុងបរិវេណព្រះឧបោសថរតនារាម ព្រះ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: sum_sarith@camnet.com.kh

កែវមរកត ព្រះបរមរាជវាំង

-អញ្ជើញចុះមូលដ្ឋានដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខចាស់ព្រឹទ្ធាចារ្យ មន្ត្រីរាជការ ប្រជាពលរដ្ឋ និងបងប្អូនប្រជាពលរដ្ឋប្រកបរបររត់ម៉ូតូឌុប ម៉ូតូកង់៣ ព្រមទាំងបានអញ្ជើញពិនិត្យទំនប់សណ្ដារស្ទឹងព្រែកត្នោត និងសួរសុខទុក្ខក្រុមការងារ របស់ក្រសួងធនធានទឹក និងឧតុនិយមដែលប្រចាំការនៅកន្លែងទំនប់បាក់ សរុបចំនួន០៦លើក នៅរាជធានីភ្នំពេញ

-អញ្ជើញចូលរួមជាកិត្តិយសអបអរសាទរពិធីសំណេះសំណាល ជាមួយក្រុមប្រឹក្សាសង្កាត់ ខណ្ឌ រាជធានី និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាព**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាចូលគោរពវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទភូមិពុល អាឌុលយ៉ាដេត ព្រះមហាក្សត្រនៃព្រះរាជាណាចក្រថៃឡង់ដ៍** នៅស្ថានទូតថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ ជូនគណៈប្រតិភូជាន់ខ្ពស់សាធារណរដ្ឋប្រជាមានិតចិន នៅព្រះរាជដំណាក់សិរីមង្គលក្នុងព្រះបរមរាជវាំង

-អញ្ជើញជាអធិបតីក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១៣ នៅវត្តកប់ស្រូវ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពលោកស្រី **សៅ ស៊ីថា** ជាប្រជាពលរដ្ឋរស់នៅផ្ទះលេខ២៣៤០ ផ្លូវលេខ២៦៣ ភូមិ១៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន ២៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន ១១២ច្បាប់ ។

**១.២.ឯកឧត្ដម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក

-អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ ខណ្ឌ រាជធានី និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាល និងបូកសរុបលទ្ធផលការងារចុះឈ្មោះបោះឆ្នោតជំហានទី១ របស់ខេត្តកំពត ចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦ ដោយមានការចូលរួមពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទូទាំងខេត្ត

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៩២ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក

-អនុញ្ញាតឲ្យគណៈប្រតិភូជាន់ខ្ពស់នៃសភាប្រឹក្សានយោបាយចិន ដឹកនាំដោយឯកឧត្តម **វ៉ាង រ៉ុង** ប្រធានគណៈកម្មាធិការសភាប្រឹក្សានយោបាយប្រជាជនចិនខេត្តក្វាងទុង ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា និងទទួលជប់លៀងជូនគណៈប្រតិភូ នៅសណ្ឋាគារ Inter-con

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រណាំងទូកង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាល ជាមួយក្រុមប្រឹក្សាសង្កាត់ ខណ្ឌ រាជធានី មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ទៅពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល

-អញ្ជើញជាអធិបតីភាពក្នុងពិធីជប់លៀងជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៅភោជនីយដ្ឋាន Jasmineភ្នំពេញ

-អញ្ជើញចូលរួមពិធីកាន់បិណ្ឌវេនទី១២-១៣ ចំនួន០៣វត្ត គឺវត្តមុនីប្រសិទ្ធីវង្ស វត្តច័ន្ទគិរីវង្ស និងវត្តព្រែកប្រាំង នៅរាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១១៩ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក:**

១.ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល

២.ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៧ ស្តីពីប្រព័ន្ធធ្វងកាត់គយ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ

៣.ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារដើម្បីអនុវត្តកញ្ចប់ទី៦ នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា

៤.ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣

៥.ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

១.កិច្ចព្រមព្រៀងស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន

២.ពិធីសារស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន

៣.ពិធីសារស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន ។

**៣. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែតុលានេះ សមាជិក-សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៣.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាលដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៥។

## ៣.២. មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-អញ្ជើញចុះជួបពិភាក្សាការងារជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងគោលបំណងសិក្សាឈ្វេងយល់ ប្រមូលព័ត៌មានអំពីវឌ្ឍនភាព និងការប្រឈមពាក់ព័ន្ធនឹងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ការដោះស្រាយទំនាស់ក្នុងសហគមន៍មូលដ្ឋាន និងការចុះឈ្មោះបោះឆ្នោត នៅសាលប្រជុំសាលាស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

## ៣.៣. មុខងារតំណាង

-បានទទួលពាក្យបណ្តឹងបានចំនួន០១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន០១ករណី ធ្វើលិខិតអន្តរាគមន៍ផ្ញើជូនទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយបានចំនួន០២ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចបានចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០២ករណី និងតំកល់ទុកមិនចាត់ការចំនួន០២ករណី ព្រមទាំងទទួលពាក្យបណ្តឹងជូនជ្រាប១១ករណី ។

-ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជាជាមួយព្រឹទ្ធសភាបារាំង ប្រជុំពិភាក្សារៀបចំសមាសភាពគណៈប្រតិភូធ្វើទស្សនកិច្ចនៅព្រឹទ្ធសភាបារាំង

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ចុះតាមដានលទ្ធផលក្រោយវេទិកាជួបសំណេះសំណាល សាកសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ និងតំណាងក្រុមប្រជាពលរដ្ឋដែលរស់នៅសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ និងសង្កាត់ឪឡោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ប្រជុំពិនិត្យ ពិភាក្សាលើគម្រោងចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន និងគម្រោងរៀបចំវេទិកាថ្នាក់ស្រុក នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ប្រជុំដើម្បីរៀបចំផែនការធ្វើបច្ចុប្បន្នភាពប្រសិទ្ធិភាពការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តបន្ទាយមានជ័យ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយប្រធានក្រុមប្រឹក្សាខេត្ត ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាព និងតាមដានលទ្ធផលក្រោយរៀបចំវេទិកា និងបើកកិច្ចប្រជុំស្តីពីការប្រមូលព័ត៌មាន និងជំរុញបូកសរុបបញ្ហា

ប្រឈមនានា ដើម្បីជួបពិភាក្សាដោះស្រាយជាមួយអាជ្ញាធរខេត្តព្រៃវែង

-អញ្ជើញចូលរួមអង្គវេទិកាស្ត្រីស្តីពី "វឌ្ឍនភាពស្ត្រីក្នុងវិស័យនយោបាយ"

-អញ្ជើញចូលរួមប្រជុំផ្តល់យោបល់ និងអនុសាសន៍លើសេចក្តីព្រាងច្បាប់ចំនួន ០៥

-អញ្ជើញចូលរួមសិក្ខាសាលាសភា ស្តីពីបទពិសោធន៍នៃដំណើរការរៀបចំថវិកាក្នុងបរិបទប្រទេសនិយាយភាសាបារាំង៖ ច្បាប់ហិរញ្ញវត្ថុ ថវិកាថ្នាក់ក្រោមជាតិ និងការអនុវត្តថវិកា រៀបចំដោយគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រឹទ្ធសភា-រដ្ឋសភា សហការជាមួយក្រុមសភាជាតិកម្ពុជាAPF សភានិយាយភាសាបារាំង និងអង្គការអន្តរជាតិនៃប្រទេសនិយាយភាសាបារាំង

-អញ្ជើញប្រជុំពិភាក្សាការងារជាមួយតំណាងវិទ្យាស្ថានសភាកម្ពុជា PIC ស្តីពីការបណ្តុះបណ្តាលកម្មសិក្សាការីនៃការិយាល័យថវិកាសភា PBO និងឈ្វេងយល់អំពីភារកិច្ច និងវិធីសាស្ត្រនៃការអនុវត្តសកម្មភាពរបស់វិទ្យាស្ថានសភាកម្ពុជា PIC

-អញ្ជើញចូលរួមសន្និសីទក្រោមប្រធានបទស្មារតីនៃសុន្ទរកថាទីក្រុងភ្នំពេញ និងប្រទេសកម្ពុជា ក្នុងឱកាសពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៥០នៃដំណើរទស្សនកិច្ចរបស់ឧត្តមសេនីយ៍ **ឆាល ដឺហ្គោល** មកប្រទេសកម្ពុជា

-អញ្ជើញធ្វើបទឧទ្ទេសនាមលើប្រធានបទ ស្តីពីការអភិវឌ្ឍ និងបទពិសោធន៍ផ្នែកលំនៅដ្ឋានរបស់អង្គការមូលនិធិអភិវឌ្ឍន៍សហគមន៍ ក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាន

-អនុញ្ញាតឲ្យតំណាងទស្សនាវដ្តីGlobal Business Fortune China Magazine ចូលជួបពិភាក្សាការងារ

-អញ្ជើញជួបពិភាក្សាការងារជាមួយ លោកបណ្ឌិត Johannes Krusemark-Camin តំណាងអង្គការមូលនិធិ Max Planck Foundation អន្តរជាតិ ស្តីពីការរៀបចំកម្មវិធីអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ

- អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **វុង ផ្សាមកេសន** ទីប្រឹក្សាផ្ទាល់សម្តេចប្រធានព្រឹទ្ធសភា និងជាអតីតសមាជិកព្រឹទ្ធសភា នីតិកាលទី១ ហើយជាអតីតអភិបាលខេត្តកោះកុង នៅវត្តអម្ពទិយារ៉ាម ហៅវត្តព្រៃស្វាយ ស្ថិតនៅភូមិព្រៃស្វាយ សង្កាត់

ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ហ៊ុល សាវ័ន្ត** អតីតសមាជិករដ្ឋសភា នៅភូមិភាគទី៨ ខេត្តស្វាយរៀង

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន១៦៧លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ចុះពិនិត្យស្ថានភាពទឹកជំនន់ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨៨លើក ។

**៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ម៉ុង ឫទ្ធី** អញ្ជើញបំពេញទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកក្នុងការអភិវឌ្ឍអាជីវកម្មប្រកបដោយចីរភាព និងចូលរួមកិច្ចប្រជុំផ្សារភ្ជាប់ព្រមទាំងទស្សនាការចាក់បញ្ចាំងខ្សែភាពយន្តខ្នាតអន្តរជាតិនៅទីក្រុងអាំស្ទែដាំ ប្រទេសហូឡង់

-ឯកឧត្តម **ឈិត គឹមយាត** និងឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៣៧ នៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា

-ឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៣៥ និងចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

-ឯកឧត្តម **អ៊ុង ទី** អញ្ជើញទៅបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីការងារសង្គម ការងារមនុស្សធម៌ ព្រមទាំងបានជួបសំណេះសំណាលជាមួយនឹងតំណាងពាណិជ្ជករចំនួន៥០រូប នៅប្រទេសម៉ាឡេស៊ី

-ឯកឧត្តម**ប៊ូ ថង** អញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយ ឯកឧត្តមឯកអគ្គរដ្ឋទូតឡាវ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០ ទំនាក់ទំនងការទូតកម្ពុជា-ឡាវ ។

-អញ្ជើញជួបពិភាក្សាការងារជាមួយ ភារធារីនៃស្ថានទូតប្រទេសជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីស្នើសុំការគាំទ្រដំណើរទស្សនកិច្ចសិក្សាឈ្វេងយល់អំពីសិទ្ធិមនុស្សនៅប្រទេសជប៉ុន ។៚

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៦

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ